ឆ្នាំ ទី ៦ លេខ ៦៣ សប្តាហ៍ ទី ៤ ថ្ងៃ ទី ២៧ ខែ សីហា ឆ្នាំ ២០០៦ រាជកិច្ច ទំព័រ ៦១១៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ....០១...បប....

ភ្នំពេញ ថ្ងៃទី....១៨....ខែ ឧសភា ឆ្នាំ២០០៦

# បទបញ្ជា
## ស្តីពី
## ការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ

ក្នុងគោលបំណង ថែរក្សាការពារនិងពង្រឹងយ៉ាងម៉ឺងម៉ាត់នូវការគ្រប់គ្រងដីព្រៃឈើគ្រប់ប្រភេទ ពីការកាប់បំផ្លាញ ទន្ទ្រាន និងហ៊ុំព័ទ្ធយកធ្វើជាកម្មសិទ្ធ **រាជរដ្ឋាភិបាលចាំបាច់ដាក់ចេញនូវបទបញ្ជាជាបន្ទាន់ ឱ្យអភិបាលខេត្ត-ក្រុង អនុវត្តដូចខាងក្រោម:**

១- ត្រូវប្រើប្រាស់អំណាចរដ្ឋ ដោយចេញដីកាជាបន្ទាន់យ៉ាងយូរបំផុត ត្រឹមថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០៦ ដោយប្រកាសបដិសេធ និងដកហូតដីព្រៃឈើគ្រប់ប្រភេទ ដែលត្រូវបានរំលោភបំពានទាំងអស់មកទុកជាសម្បត្តិរដ្ឋវិញតាមការចាំបាច់ ។

២- ដីកានេះត្រូវកំណត់រយៈពេល ៣០ ថ្ងៃ ដើម្បីឱ្យគេធ្វើការប្តឹងតវ៉ា ហើយក្នុងករណីមិនមានអ្នកប្តឹងទាមទារទេនោះ អភិបាលខេត្ត-ក្រុង ត្រូវរាយការណ៍ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មាធិការជាតិដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រានដុត ឈូសឆាយនិងហ៊ុំព័ទ្ធដីព្រៃឈើវាតយកដីធ្វើកម្មសិទ្ធិ ដើម្បីរាជរដ្ឋាភិបាលចេញអនុក្រឹត្យកំណត់ទុកដីទាំងនោះជាសម្បត្តិរដ្ឋ។

៣- ត្រូវពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងដីព្រៃឈើគ្រប់ប្រភេទ ដែលមានជាធរមាន ឱ្យបានត្រឹមត្រូវនិងម៉ឺងម៉ាត់បំផុត ជាពិសេសអំពីទោសប្បញ្ញត្តិចំពោះជនទាំងឡាយណាដែលបានរំលោភបំពានលើដីព្រៃឈើគ្រប់ប្រភេទ យកធ្វើជាកម្មសិទ្ធិនោះ ។

៤- ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គបញ្ជាការដ្ឋានកងយោធពលខេមរៈភូមិន្ទ កងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការដ្ឋាននគរបាលជាតិ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវសហការអនុវត្តបទបញ្ជានេះ ក្នុងស្មារតីទទួលខុសត្រូវ និងឱ្យមានប្រសិទ្ធិភាពខ្ពស់ ហើយរាយការណ៍អំពីលទ្ធផលជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មាធិការជាតិដើម្បីទប់ស្កាត់ លុបបំបាត់និងបង្ក្រាបការកាប់រានដុត ឈូសឆាយ និងហ៊ុំព័ទ្ធដីព្រៃឈើវាតយកដីធ្វើកម្មសិទ្ធិតាមករណីជាក់ស្តែងនិមួយៗ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**ចម្លងជូន**
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- អគ្គលេខាធិការដ្ឋានប្រតិបត្តិ គជដព
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចចំណុចទី ៤
- ឯកសារ កាលប្បវត្តិ